**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# ញត្តិគាំទ្រ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមប្រកាសគាំទ្រពេញទំហឹងចំពោះការថ្លែងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ដែលបានសម្រេចប្រគល់ភារកិច្ចជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ក្នុងការសិក្សាធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត ដើម្បីដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតចំពោះជនណាដែលមិនទៅបោះឆ្នោត។

តាមគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លាប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** តាមរយៈសារសំឡេងកាលពីយប់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ នេះ គឺពិតជាមានតម្លៃបំផុតចំពោះពលរដ្ឋគ្រប់អាយុបោះឆ្នោតគ្រប់រូបក្នុងការធ្វើជាពលរដ្ឋដ៏ល្អរបស់ប្រទេសជាតិក្នុងសង្គមប្រជាធិបតេយ្យ ជាពិសេសចំពោះអ្នកដឹកនាំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលការធ្វើវិសោធនកម្មច្បាប់នេះមានលក្ខណៈស្របតាមខ្លឹមសារបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងមិនបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពលរដ្ឋឡើយ។ ក្នុងន័យនេះអ្នកដែលមិនទៅបោះឆ្នោតដោយគ្មានមូលហេតុសមរម្យតាមផ្លូវច្បាប់ នឹងត្រូវចាត់ទុកថាបានបាត់បង់នូវលក្ខខណ្ឌក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោត ប៉ុន្តែអ្នកទាំងនោះនៅតែមានសិទ្ធិអាចទៅបោះឆ្នោតក្នុងនាមជាពលរដ្ឋដូចពលរដ្ឋទូទៅ។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមប្រកាសគាំទ្រទាំងស្រុងចំពោះរាល់គំនិតផ្តួចផ្តើម និងការសម្រេចចិត្តដ៏ថ្លៃថ្លាប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងបុព្វហេតុជាតិ សុខសន្តិភាព សណ្តាប់ធ្នាប់ របៀបរៀបរយ សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរបស់ប្រជាជាតិខ្មែរ ពិសេសភាពរឹងមាំនៃនីតិរដ្ឋ និងប្រជាធិបតេយ្យនៅកម្ពុជា ដើម្បីភាពសុខសាន្ត និងសម្បូររុងរឿងជាដរាបរបស់សង្គមជាតិយើង៕

ថ្ងៃចន្ទ ៩ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២៣